

PreK4 ME ការផ្សារភ្ជាប់គ្រួសារ

# មេរៀនទី 1 ៖ *គ្រួសារ*

## ***ទិដ្ឋភាពទូទៅនៃមេរៀនទី 1 ៖ គ្រួសារ***

*ក្នុងខែនេះ យើងនឹងស្វែងយល់អំពីគ្រួសារសិស្ស ការផ្សារភ្ជាប់ទំនាក់ទំនង និងការជួយគ្នានៃសមាជិកគ្រួសាររបស់ពួកគេ ។ តាមរយៈការរៀនសូត្រនេះ យើងនឹងស្វែងយល់ពីរបៀបដែលក្រុមគ្រួសារពួកគេធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហា ដោះស្រាយទំនាស់ និងការសម្រេចចិត្តចំពោះបញ្ហាសំខាន់ៗ ព្រមទាំងរៀនសូត្រអំពីតួនាទីផ្សេងៗ ក៏ដូចជាការទទួលខុសត្រូវផ្សេងៗក្នុងសង្គមគ្រួសារ។ ក្នុងនេះផងដែរ យើងក៏នឹងធ្វើការរួមគ្នា ដើម្បីបង្កើតបានមូលដ្ឋានគ្រឹះនៃជំនាញជុំវិញតួអក្សរ និងសម្លេងការនិយាយរបស់ពួកគេ ។ យើងកំពុងជួបប្រទះជុំវិញបទពិសោធន៍ផ្សេងមួយទៀត របស់មិត្តរួមថ្នាក់ ក៏ដូចជាបទពិសោធន៍ចំពោះរបៀបដោះស្រាយបញ្ហានៅក្នុងថ្នាក់រៀនរបស់យើង ។*

*សូមបន្តអានទៅមុខទៀត ដើម្បីរកមើលថាតើមានអ្វីកំពុងតែកើតឡើង នៅក្នុងថ្នាក់រៀន PreK របស់យើង ដើម្បីពាំនាំបរិដ្ឋានការរៀនសូត្របែបនៅផ្ទះ មកទៅឲ្យកូនៗរបស់អ្នកយើងរៀងៗខ្លួន!*

### សៀវភៅសំខាន់ៗនៃមេរៀនទី 1




*Peter's Chair*

រៀបរៀងដោយ Ezra Jack Keates




*The Hello, Goodbye Window*

រៀបរៀងដោយ Norton Juster និង Chris Raschka




*Time for Bed*

រៀបរៀងដោយ Mem Fox




*Families*

រៀបរៀងដោយ Shelley Rotner និង Sheila M. Kelly

រូបភាពដកស្រង់ចេញពី Amazon.com

### សៀវភៅផ្សេងទៀតដែលយើងអាន ៖

Cry Baby រៀបចំដោយ ៖ Karen Beaumont

Sometimes I am Bambaloo រៀបចំដោយ ៖ Rachel Vail

Corduroy រៀបចំដោយ ៖ Don Freeman

A Pig is Big រៀបចំដោយ ៖ Douglas Florian

Shoes, Shoes, Shoes

រៀបចំដោយ ៖ Ann Morris

## ចម្រៀង ការលេងពាក្យ និងតួអក្សរ

នេះជាម៉ោងដែលយើងពាំនាំការរៀនសូត្រមកឲ្យសិស្សតាមរយៈសកម្មភាពសប្បាយៗ សម្រាប់សិស្សក្នុងក្រុមទាំងមូល ។ យើងកំពុងចាប់ផ្តើមរាប់... ជាមួយនឹងពាក្យថាកង្កែប ៖

### កង្កែបបៃតង 5 មានស្នាមអុជលើស្បែក

កង្កែបបៃតង 5 ដែលមានស្នាមអុជលើស្បែក ទំលើដុំឈើមានស្នាមអុជ កំពុងស៊ីសត្វល្អិតជាចំណីយ៉ាងឆ្ងាញ់ .. ឆ្ងាញ់! ឆ្ងាញ់!!

កង្កែបមួយបានលោតចូលក្នុងបឹង ដ៏ស្អាត ហើយមនោរម្យ ។ ឥឡូវនៅសល់កង្កែប បៃតង 4 មានស្នាមអុជលើស្បែកទំលើដុំឈើ.. ព្រុប! ព្រុប!

កង្កែបបៃតង 4 មានស្នាមអុជលើស្បែក ទំលើដុំឈើមានស្នាមអុជ កំពុងស៊ីសត្វល្អិតជាចំណីយ៉ាងឆ្ងាញ់បំផុត.. ឆ្ងាញ់! ឆ្ងាញ់!!

កង្កែបមួយបានលោតចូលក្នុងបឹង ដ៏ស្អាត ហើយមនោរម្យ ។ ឥឡូវនៅសល់កង្កែបបៃតង 3 មានស្នាមអុជលើស្បែក.. ព្រុប! ព្រុប!

កង្កែបបៃតង 3 មានស្នាមអុជលើស្បែក ទំលើដុំឈើមានស្នាមអុជ កំពុងស៊ីសត្វល្អិតជាចំណីយ៉ាងឆ្ងាញ់.. ឆ្ងាញ់! ឆ្ងាញ់!!

កង្កែបមួយបានលោតចូលក្នុងបឹង ដ៏ស្អាត ហើយមនោរម្យ ។ ឥឡូវនៅសល់កង្កែបបៃតង 2 មានស្នាមអុជលើស្បែក.. ព្រុប! ព្រុប!

កង្កែបបៃតង 2 មានស្នាមអុជលើស្បែក ទំលើដុំឈើមានស្នាមអុជ កំពុងស៊ីសត្វល្អិតជាចំណីយ៉ាងឆ្ងាញ់.. ឆ្ងាញ់! ឆ្ងាញ់!!

កង្កែបមួយបានលោតចូលក្នុងបឹង ដ៏ស្អាត ហើយមនោរម្យ ។ ឥឡូវនៅសល់តែកង្កែបបៃតង 1 មានស្នាមអុជលើស្បែក.. គ្លុប! គ្លុប!

កង្កែបបៃតង 1 មានស្នាមអុជលើស្បែក ទំលើដុំឈើមានស្នាមអុជ កំពុងស៊ីសត្វល្អិតជាចំណីយ៉ាងឆ្ងាញ់.. ឆ្ងាញ់! ឆ្ងាញ់!!

កង្កែបមួយបានលោតចូលក្នុងបឹង ដ៏ស្អាត ហើយមនោរម្យ ។ ឥឡូវមិនមានកង្កែបបៃតង (0) មានស្នាមអុជលើស្បែកទៀតទេ ទំលើដុំឈើមានស្នាមអុជទៀតទេ .. គ្លុប! គ្លុប!

សូមអានទំព័រម្ខាងទៀតអំពីសកម្មភាពនៅផ្ទះ

# ចូរបង្កើតការរៀនសូត្រនៅផ្ទះ ដោយប្រើសកម្មភាពបន្ថែមទាំងអស់នេះ!

| សកម្មភាពនេះជ្រោមជ្រែងដល់ភាសាមនោសញ្ចេតនាសង្គម និងបទដ្ឋានការសិក្សាសង្គម របស់យើង | សកម្មភាពនេះជ្រោមជ្រែងដល់បទដ្ឋានអក្សរសាស្ត្រ និងសិល្បៈការច្នៃប្រឌិត របស់យើង | សកម្មភាពនេះជ្រោមជ្រែងដល់បទដ្ឋានការសិក្សាគណិតវិទ្យារបស់យើង |
|---|---|---|
| **រូបថតគ្រួសារ**<br>បើអ្នកមានអាល់ប៊ុមរូបថតគ្រួសារ—សូមយករូបថតនោះមកមើលជាមួយកូនអ្នក ។ និយាយជាមួយពួកគេថាក្នុងរូបជានរណា ត្រូវជាអ្វីគាត់ និងអនុស្សាវរីយ៍នាពេលនោះ ។ | **ចាប់ផ្តើមជាមួយនឹង**<br>ឲ្យកូនរបស់អ្នករករបស់ចំនួនបីយ៉ាងនៅជុំវិញផ្ទះ ដែលផ្តើមដោយពាក្យដែលមានសម្លេងដូចឈ្មោះរបស់គេ រួចឲ្យពួកគេ គូររូបភាពនៃរបស់ទាំងនោះ ។ | **ការប្រមាញ់គណិតវិទ្យា**<br>នាំគ្នាចេញប្រមាញ់រតនៈសម្បត្តិគណិតវិទ្យា! ណែនាំកូនរបស់អ្នកឲ្យនាំគ្នាស្វែងរករបស់ 2 ឬ 3 នៅជុំវិញផ្ទះដែលដូចគ្នា (ខ្មៅដៃពីរ គម្របដបពីរ ។ល។) ។ ឲ្យកូនអ្នកយករបស់ទាំងនោះមកតម្រៀបគ្នាជាជួរ ឬយកវាបិទជាប់នឹងក្រដាស ។ ឲ្យកូនអ្នករាប់ចំនួនរបស់ទាំងនោះ ។ |

*គន្លឹះក្នុងការនិទានរឿងឲ្យកូនស្តាប់ ៖*

⇒ រកកន្លែងដែលកក់ក្តៅ ស្ងាត់ស្រួល ដែលមិនមាននរណាមករំខាន

⇒ ពេលអ្នកកំពុងអានរឿងឲ្យកូនស្តាប់ ត្រូវចង្អុលពាក្យប្រាប់ពួកគេ នៅតាមបន្ទាត់នីមួយៗ ដោយប្រើម្រាមដៃ

⇒ពន្យល់អត្ថន័យពាក្យថ្មី ឬពាក្យពិបាកៗ ក្នុងពេលកំពុងតែអាន



រូបភាពដកស្រង់ពី Pixabay

បណ្តាំចំពោះគ្រួសារ និងអ្នកមើលថែក្មេង ៖

នៅគ្រប់ដំណាក់កាលលូតលាស់របស់ក្មេង ប្រការសំខាន់គឺអ្នកត្រូវតែដឹងអំពីសកម្មភាពការរៀនសូត្ររបស់ពួកគេពេញមួយថ្ងៃ។ ចំពោះឪពុកម្តាយដែលជាអ្នកធ្វើការ ចំណុចនេះ តែងតែមានការលំបាក តែយើងអាចធ្វើឲ្យវាងាយស្រួលបានតាមរយៈការទំនាក់ទំនងដោយចំហជាមួយនឹងអ្នកមើលថៃ និងអប់រំកូនអ្នក ។ ត្រូវប្រាកដថា អ្នកមើលថៃកូនអ្នក មានព័ត៌មានបច្ចុប្បន្នភាព សម្រាប់ទំនាក់ទំនងជាមួយអ្នក ។ ត្រូវសួរនាំអ្នកមើលថៃកូនអ្នកឲ្យបានញឹកញាប់ គឺអាចសួរនាំប្រចាំថ្ងៃ ដើម្បីឲ្យអ្នកបានដឹងថា តើកូនអ្នកកំពុងរៀនអំពីអ្វី ហើយថាតើគាត់មានអាកប្បកិរិយាបែបណា ។ ត្រូវអនុវត្តសកម្មភាពនៅផ្ទះ ជាមួយកូនអ្នក ដើម្បីជ្រោមជ្រែងអំពីអ្វីដែលកូនអ្នកបានរៀននៅមត្តេយ្យ ឬទារកដ្ឋាន ។ ការសួរនាំបែបនេះ ជាមួយអ្នកមើលថៃកូនអ្នក និងគ្រូរបស់គាត់ គឺមិនត្រឹមតែអាចជួយដល់ការរៀនសូត្រ ការលូតលាស់សង្គម និងអារម្មណ៍របស់កូនអ្នកទេ តែវាអាចជួយឲ្យមនោសញ្ចេតនារបស់អ្នក និងកូនអ្នកផ្សាភ្ជាប់គ្នាថែមទៀត ។

សូមកុំភ្លេចថា គ្រប់ការប្រាស្រ័យទាក់ទងជាមួយកូនអ្នក គឺសុទ្ធតែជាការរៀនសូត្រទាំងអស់ ហើយការរៀនសូត្របែបនេះ វាកើតឡើងនៅតាមកន្លែងផ្សេងៗទៀត ក្រៅពីនៅសាលារៀន ។

ដកស្រង់ពី ៖ https://eclkc.ohs.acf.hhs.gov/parenting/article/you-your-preschool-child#Needs